00846902

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / 09 / 2012
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

002/19-09-2007-ECCC/TC
E1/119

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសជ

## ថ្ងៃ សុក្រ ទី ៣១ ខែ សីហា ឆ្នាំ ២០១២

## សវនាការលើបញ្ហាកាយសម្បទា និងសតិបញ្ញាស្មារតីជនជាប់ចោទ

## អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ- ថ្ងៃទី ១០៦

រៀបចំដោយ: ឌុច ផារី និង Roger PHILLIPS

| <u>កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ</u> |
| --- |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ គុលវុឌ្ឍី, លោក Roger PHILLIPS, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ចាន់ ដារាវស្មី, លោក RAYNOR Keith, លោក Tarik ABDULHAK, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ អៀង ធីរិទ្ធ និង អៀង សារី (ចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោម) |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង ធីរិទ្ធ៖ លោក ផាត់ ពៅស៊ាង, លោកស្រី Diana ELLIS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោកស្រី Beini YE, លោក វ៉ែន ពៅ, លោក ហុង គីមសួន, លោកស្រី ស៊ីន សូវ៉ន, លោក សំ សុគង់ |
| អ្នកជំនាញ៖ លោក ហួត លីណា, លោក Seena FAZEL, លោក John A. CAMPBELL |
| មន្រ្តីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុំ អារុណ |
| ផ្សេងៗ៖ លោកស្រី Susan LAMB, លោក Simon MEISENBERG, លោក Yiqiang LIU, កញ្ញា Sonia MESSAOUDI, លោក ឡាយ ណារ៉ា, លោក ម៉ៀច សុវណ្ណា, លោកស្រី Seynabou DIOP |

**<u>ពេលវេលាទូទៅរបស់តុលាការ៖</u>**

| ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.១០ | បញ្ចប់ម៉ោង៖ ១៦.១៥ |
|---|---|---|
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកវេលាល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៣០ | បញ្ចប់ម៉ោង៖ ១៤.៤៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង និង ០៥ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញា | អង្គជំនុំជម្រះ | ៩.០៩ | ៩.១៤ |
| ការតាំងសំណួរដល់អ្នកជំនាញលោក ហួត លីនណា លោក Seena FAZEL និង លោក John A. CAMPBELL | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>មេធាវីការពារក្តី អៀង ធីរិទ្ធ | ០៩.១៤<br>១០.២១<br>១១.២០<br>១៣.៣០ | ១០.២០<br>១១.១៩<br>១២.០៥<br>១៤.១៧ |
| សំណើសុំឱ្យមានវត្តមានរបស់លោកស្រី អៀង ធីរិទ្ធ ក្នុងពេលធ្វើសេចក្តីសន្និដ្ឋាន | មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១៤.២៤ | ១៤.២៥ |

| | | | |
|---|---|---|---|
| ការធ្វើសេចក្ដីសន្និដ្ឋានរបស់ភាគី | សហព្រះរាជអាជ្ញា | ១៤.៤៣ | ១៥.២២ |
| | មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ១៥.២២ | ១៥.៤០ |
| | មេធាវីការពារក្ដី អៀង ធីរិទ្ធ | ១៥.៤០ | ១៦.១៣ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញា</u>**

សហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីប្រគល់ឯកសារមួយចំនួនទាក់ទងនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ទៅឱ្យសាស្ត្រាចារ្យ ចក ធីដា។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើ និងស្នើឱ្យក្រឡាបញ្ជីរៀបចំនូវបញ្ជីឯកសារ ដើម្បីប្រគល់ទៅឱ្យសាស្ត្រាចារ្យ ចក ធីដា។

**<u>ការតាំងសំណួរដល់អ្នកជំនាញលោក ហួត ស៊ីនណា, លោក Seena FAZEL និងលោក John CAMPBELL</u>**

អង្គជំនុំជម្រះតាំងសំណួរដល់អ្នកជំនាញទាំងបីរូប។ បន្ទាប់មក សហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីការពារក្ដីរបស់លោកស្រី អៀង ធីរិទ្ធ តាំងសំណួរដល់អ្នកជំនាញ។

**<u>សំណើសុំឱ្យមានវត្តមានរបស់លោកស្រី អៀង ធីរិទ្ធ ក្នុងពេលធ្វើសេចក្ដីសន្និដ្ឋាន</u>**

មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឱ្យមានវត្តមានរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងពេលធ្វើសេចក្ដីសន្និដ្ឋាន ។ អង្គជំនុំជម្រះកត់សម្គាល់ថា សំណើខាងលើមិនមានភាពចាំបាច់ និង សម្រេចបដិសេធលើសំណើសុំនេះ ។ អង្គជំនុំជម្រះបង្គាប់ឱ្យលោកស្រី អៀង ធីរិទ្ធ បន្តតាមដានដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសវនាការ ។

**<u>ការធ្វើសេចក្ដីសន្និដ្ឋានរបស់ភាគី</u>**

លោកស្រីចៅក្រម Cartwright ស្នើសុំឱ្យភាគីធ្វើការឆ្លើយតបទៅនឹងសំណួរចំនួនបីក្នុងពេលភាគីធ្វើសេចក្ដីសន្និដ្ឋាន។ ទីមួយ៖ តើជនជាប់ចោទមាន ឬមិនមាននូវសម្បទានិងសត្តិបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះដែរ ឬទេ។ ទីពីរ៖ ទាក់ទងនឹងការដោះលែង ឬបន្តការឃុំខ្លួន ។ទីបី៖ តើមានលក្ខខណ្ឌអ្វីខ្លះចំពោះការដោះ លែងជនជាប់ចោទ និងមូលដ្ឋានផ្លូវច្បាប់ចំពោះលក្ខខណ្ឌទាំងនោះ ។

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីការពារក្ដីរបស់លោកស្រី អៀង ធីរិទ្ធ ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|
| N/A | E111/3.3 | 00739081-00739085 00738563-00738565 | ឧបសម្ព័ន្ធ ខ៖ ឯកសារវេជ្ជសាស្ត្រ និង ឯកសារបានមកពីប្រធានមន្ទីរឃុំឃាំង ចងក្រងនៅក្រោយពេលចាប់ខ្លួន អៀង ធីរិទ្ធ នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ Annex B: Medical documents and documents from the head of the Detention Unit compiled after the arrest the IENG Thirith on 14 November 2007 | C | | | |
| N/A | E138/1/7/12 | 00810694-00810697 00809103-00809104 00810692-00810693 | របាយការណ៍នៃកម្មវិធីបណ្ដុះបណ្ដាលស្ដីពីការលើកកម្ពស់សតិបញ្ញាស្មារតីឲ្យលោកស្រី អៀង ធីរិទ្ធ ដែលមានធ្វើនៅ អ.វ.ត.ក Report on cognitive stimulation training for IENG Thirith Rapport sur le stage de stimulation de la fonction cognitive de IENG Thirith effectué aux cetc | S | | | |
| N/A | E138/1/8/2.2 | 00841087-00841087 00839570-00839570 | កំណត់ហេតុរបស់គិលានុបដ្ឋាយិកាដោយផ្អែកលើពិន្ទុនៃតារាងវាយតម្លៃ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២ The notes by the nurses from the score on 12 July 2012 | S | | | |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះបង្គាប់ឱ្យក្រឡាបញ្ជីផ្ដល់ឯកសារ E29/1, E37/9/9, E63/3/6.1, E62/3/6, E62/3/12, E111/8, E138/1/7/12, E138/1/7/4 ទៅឱ្យសាស្ត្រាចារ្យ ចក ធីដា ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ នាំអ្នកជំនាញត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់វិញ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ និង អៀង សារី ត្រឡប់ទៅកាន់មន្ទីរ

ឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ អៀង សារី មកកាន់បន្ទប់សវនាការវិញនៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ ។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ច័ន្ទ ទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផារី Roger PHILLIPS